# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២០ អនក្រ.បក

**<u>អនុក្រឹត្យ</u>**

**ស្តីពី**

**នីតិវិធីនៃការបើកផ្តល់មុន ដោយអាណត្តិបើកប្រាក់ សំរាប់គោលដៅជួសជុលផ្លូវថ្នល់**

**តាមរូបមន្ត ៥០% រដ្ឋ និង ៥០% ប្រជាពលរដ្ឋ**

៚

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ-ឆ្នាំ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ស្ថាប័ន ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១:** អនុក្រឹត្យនេះមានគោលបំណងកែសម្រួលនីតិវិធី និង បែបបទបញ្ចេញអាណត្តិបើកប្រាក់សំរាប់គោលដៅ ជួសជុលផ្លូវថ្នល់ តាមរូបមន្ត ៥០% រដ្ឋ និង ៥០% ប្រជាពលរដ្ឋ ។ គោលដៅនៃកិច្ចប្រតិបត្តិការនេះ គឺដើម្បីធានាសម្រេចបាននូវប្រសិទ្ធភាពចំណាយ សំខាន់ធានាបាននូវភាពទៀងទាត់ និងទាន់ពេលវេលា ដោយផ្តល់សិទ្ធិ និងការទទួលខុសត្រូវចំណាយទាំងស្រុងជូនសាលាខេត្ត-ក្រុង ។

**មាត្រា២:** ដោយបដិប្បញ្ញត្តិទៅនឹងមាត្រា ៨ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ និងមាត្រា ៩ នៃអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ស្ថាប័ន ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល ការបើកផ្តល់មុន សំរាប់មុខសញ្ញាចំណាយជួសជុលផ្លូវថ្នល់ តាមរូបមន្ត ៥០% រដ្ឋ និង ៥០% ប្រជាពលរដ្ឋ ត្រូវធ្វើឡើងដោយអាណត្តិបើកប្រាក់ ។

**មាត្រា៣:** អនុញ្ញាតអោយបើកផ្តល់តាមរយៈអាណត្តិបើកប្រាក់ នូវចំណែក ៥០% របស់រដ្ឋ សំរាប់មុខសញ្ញាចំណាយ ជួសជុលផ្លូវថ្នល់ តាមរូបមន្ត ៥០% រដ្ឋ និង ៥០% ប្រជាពលរដ្ឋ ដោយតម្រូវអោយមានភ្ជាប់មកជាមួយ នូវបញ្ជីប៉ាន់តម្លៃ និងសក្ខីប័ត្របញ្ជាក់ពីការទទួលប្រាក់បដិភាគពីប្រជាពលរដ្ឋសំរាប់ផ្លូវនីមួយៗ ដែលចេញដោយរតនាគារ ឬធនាគារជាតិនៃកម្ពុជា ដើម្បីទុកជូនសាលាខេត្ត-ក្រុងធ្វើការទូទាត់ជូនអ្នកទទួលការតាមនីតិវិធីហិរញ្ញវត្ថុ ជាធរមាន ។

**មាត្រា៤:** មុខចំណាយនេះ ត្រូវអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ ជាធរមាន ។

**មាត្រា៥:** សាលាខេត្ត-ក្រុងមានភារកិច្ចធ្វើរបាយការណ៍ចំណាយផ្ញើរជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីគំរោងនីមួយៗត្រូវបានអនុវត្តចប់សព្វគ្រប់ ។ ក្នុងករណីមានប្រាក់នៅសល់ ត្រូវបង់ចូលថវិការដ្ឋវិញ ។

**មាត្រា៦:** មុខចំណាយនេះ ត្រូវស្ថិតក្រោមកម្មវត្ថុនៃការធ្វើសវនកម្មតាមក្រោយដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ/និង អាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា៧:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង-ស្ថាប័នពាក់ព័ន្ធ និង អភិបាលគ្រប់ខេត្ត-ក្រុង មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ២
- កាលប្បវត្តិ-ឯកសារ